| | - **ក្លឹបហ្វ្រេនឡ:** កំពុងផ្តល់សេវាសកម្មភាពផ្នែកវប្បធម៌ផ្សេងៗ ចំនួន ១០០,០០០ រួមមាន រាំ ល្ខោន បណ្ណាល័យ គំនូរ ដល់កុមារទាំងអស់នៅមជ្ឈមណ្ឌលអប់រំ និងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងមួយឆ្នាំ<br>- ក្លឹបហ្វ្រេនឡនឹងបើកសម្រាប់កុមារ/យុវវ័យនៅតាមផ្លូវចំនួន ២ដងក្នុងមួយ សប្តាហ៍ ដោយផ្តល់សេវានៃសកម្មភាពផ្នែកវប្បធម៌ និងកីឡាចំនួន ៣,៥០០ដង ដល់ពួកគេ<br>- ក្លឹបហ្វ្រេនឡកំពុងរៀបចំសកម្មភាពទៅខាងក្រៅសម្រាប់កុមារ និងយុវវ័យនៅក្នុងមជ្ឈមណ្ឌលអប់រំ និងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយផ្តល់សេវាកម្មចំនួន ១,២០០ ក្នុងមួយឆ្នាំ | **ក្លឹបហ្វ្រេនឡ:** ជាមណ្ឌលអប់រំរបស់អង្គការមិត្តសំឡាញ់ ដែលកុមារ/យុវវ័យអាចអនុវត្តន៍សកម្មភាពកំសាន្តសប្បាយ និងវប្បធម៌ រួមមាន កីឡា គំនូរ ផាត់ពណ៌ បណ្ណាល័យ រាំ និងតន្ត្រី។<br>- ក្លឹបហ្វ្រេនឡ កំពុងផ្តល់សេវាផ្នែកវប្បធម៌ផ្សេងៗចំនួន ២៥,០៣៥ (ស្រី១,០៤៧) រួមមានៈ រាំ ល្ខោន បណ្ណាល័យ គំនូរ ដល់កុមារទាំងអស់ នៅមជ្ឈមណ្ឌលអប់រំ និងមជ្ឈមណ្ឌលណ្តុះបណ្តាលវិជ្ជាជីវៈ)។<br>- ក្លឹបហ្វ្រេនឡ បានបើកសម្រាប់កុមារ/យុវវ័យមកពីក្រៅចំនួន ២ដងក្នុងមួយសប្តាហ៍ ដោយផ្តល់សេវានៃសកម្មភាពផ្នែកវប្បធម៌ និងកីឡាចំនួន ៨១៦ ដង (ស្រី១៥២ដង) ដល់ពួកគេ។<br>- ក្លឹបហ្វ្រេនឡបានរៀបចំសកម្មភាពទៅខាងក្រៅសម្រាប់កុមារនិងយុវវ័យ នៅក្នុងមជ្ឈមណ្ឌលអប់រំ និងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយ ផ្តល់សេវាចំនួនសេវាកម្មចំនួន ២១៤ដង (ស្រី ៩២ដង)។<br>**ព្រឹត្តិការណ៍និងកំណត់សម្គាល់ពិសេស**<br>- កុមារ/យុវវ័យចំនួន បានចូលរួមសំដែងនៅក្នុងកម្មវិធីហ្វាន់ហ្វែរ បុណ្យនៃក្តីស្រឡាញ់ ការសំដែងប្រចាំត្រីមាស ការប្រកួតកីឡាបាល់បោះ និងបាល់ទាត់ នៅមជ្ឈមណ្ឌល បណ្តុះបណ្តាលវិជ្ជាជីវៈនៃអង្គការមិត្តសំឡាញ់ ដែលមានអ្នកចូល |

| | | |
|---|---|---|
| | | រួមទស្សនាជាង ២,១០០ នាក់ ។<br>- កុមារចំនួន ៧៧ នាក់(ស្រី ៥៨នាក់) បានចូលរួមប្រកួតកីឡាទ្រីយ៉ាត្លុង ប៉េតង់ ហែលទឹក នៅខាងក្រៅជាមួយអង្គការដៃគូ និងក្លឹបកីឡាផ្សេងទៀត ជាលទ្ធផល កុមារមិត្តសំឡាញ់បានទទួលជ័យលាភីលេខ១ និងលេខ៣ ឧបត្ថម្ភគាំទ្រដោយធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា។<br>- យុវវ័យចំនួន ១៥នាក់(ស្រី ០៨នាក់) បានចូលរួមការប្រកួតប្រលងចំរៀងនៅទូរទស្សន៍អាស៊ីអាគ្នេយ៍ នៅក្នុងកម្មវិធីតារាសម័យថ្មី។ |
| **៤.៤ ក្រុមសមាហរណកម្ម**<br>ផ្តល់ការគាំទ្រ ដល់កុមារ ២០០ នាក់ក្នុងមួយឆ្នាំដើម្បីសមាហរណកម្មទៅកាន់ គ្រួសារ (គ្រួសារបង្កើត គ្រួសារសាច់ញាតិ និងគ្រួសារធម៌) នៅតាមបណ្តាខេត្តនានា។ | - បទដ្ឋាននៃនីតិវិធីលើសមាហរណកម្ម (SoPs)នឹងកែលំអ បកប្រែ និងអំណើការដោយក្រុមការងារនៅចុងឆ្នាំ ២០១២។<br>- កិច្ចសហការជាមួយរាជរដ្ឋាភិបាល និងអង្គការដៃគូត្រូវបានចាប់ផ្តើមតាមរយៈការប្រជុំ និងការបណ្តុះបណ្តាល<br>- នឹងរៀនចំប្រជុំគណៈកម្មាធិការគ្រួសារធម៌ ចំនួន ៤ដងក្នុង១ ឆ្នាំ<br>- កុមារចំនួន ១០០ នាក់ បានគាំទ្រលើការសមាហរណកម្មគ្រួសាររបស់ពួកគេ (រួមបញ្ចូលគ្រួសារផ្ទាល់ គ្រួសារសាច់ញាតិ )ឬរស់នៅឯករាជ្យ នៅក្នុង ខេត្តរបស់ពួកគេ ក្នុង១ ឆ្នាំ<br>- កុមារចំនួន១០នាក់ នឹងទទួលបានគាំទ្រលើការសមាហរណកម្មទៅកាន់គ្រួសារធម៌ ក្នុង១ ឆ្នាំ<br>- កុមារចំនួន ៥០នាក់ នឹងទទួលបានគាំទ្រលើការសមាហរណកម្មទៅសាលារដ្ឋក្នុងខេត្តរបស់គេក្នុង១ ឆ្នាំ។ | - បទដ្ឋាននៃនីតិវិធីលើសមាហរណកម្មកំពុងព្រាងនៅឡើយក្នុងត្រីមាសនេះ។<br>- អង្គការមិត្តសំឡាញ់ត្រូវបានអញ្ជើញមន្ទីរសង្គមកិច្ចរាជធានី/ ខេត្តចំនួន ០៨ រួមមាន រាជធានីភ្នំពេញ កំពង់ស្ពឺ ស្វាយរៀង ពោធិ៍សាត់ បាត់ដំបង សៀមរាប ព្រៃវែង និង បន្ទាយមានជ័យ ដើម្បីចូលរួមកិច្ចប្រជុំស្តីពីការសហការលើការងារសមាហរណកម្ម។<br>- បានសហការជាមួយមន្ត្រីសង្គមកិច្ច និងអង្គការដៃគូលើការងារ សមាហរណកម្ម រួមមានៈ ការស្វែងរក ការវាយតម្លៃ ផែនការគ្រួសារ សមាហរណកម្ម និងការតាមដាន នៅ ២៤ខេត្ត/ ក្រុង។<br>- បានរៀបចំប្រជុំគណៈកម្មាធិការគ្រួសារធម៌ចំនួន ១ដង ក្នុងត្រីនេះ នៅខេត្តអង្គការប្រេដ្យអិនធើណាស៊ិនណល រាជធានីភ្នំពេញ។<br>- កុមារ/យុវវ័យចំនួន ៣២នាក់ (ស្រី០៧នាក់)បានគាំទ្រលើការសមាហរណកម្មគ្រួសាររបស់ពួកគេ (រួមបញ្ចូលទាំងផ្ទាល់ និងសាច់ញាតិ)ក្នុងនោះមាន ១៣ នាក់ |

| | | |
|---|---|---|
| | - កុមារចំនួន ៣០០ នាក់ នៅសាលារដ្ឋ នឹងទទួលបានការគាំទ្រដើម្បីបន្តការសិក្សានៅសាលារដ្ឋក្នុងខេត្តរបស់ពួកគេ ក្នុង១ឆ្នាំ<br>- យុវវ័យចំនួន ២០នាក់ នឹងជួយស្វែងរកការងារឱ្យធ្វើ របង្កើតមុខរបរ ដោយខ្លួនឯង នៅខេត្តរបស់ពួកគេ ក្នុង១ឆ្នាំ<br>- យុវវ័យចំនួន ៧០ នាក់នឹងត្រូវបានតាមដានលើការងារឬការចាប់ផ្តើមអាជីវកម្មផ្ទាល់ខ្លួនរបស់ពួកគេនៅក្នុងខេត្តរបស់ពួកគេក្នុង១ឆ្នាំ<br>- គ្រួសាររស់នៅតាមផ្លូវចំនួន ១៥ គ្រួសារ នឹងទទួលបានគាំទ្រឱ្យត្រឡប់ទៅស្រុកកំណើតវិញក្នុង១ឆ្នាំ<br>- គ្រួសារចំនួន១០ នឹងទទួលបានការបណ្តុះបណ្តាល និងគាំទ្រសំរាប់អាជីវកម្មខ្នាតតូចនៅក្នុងខេត្តរបស់ពួកគេក្នុង១ឆ្នាំ<br>- កុមារ/យុវវ័យចំនួន ២៥នាក់ នឹងទទួលបានគាំទ្រក្នុងការទទួលអត្តសញ្ញាណប័ណ្ណ សំបុត្រកំណើត នៅខេត្តរបស់ពួកគេក្នុង១ឆ្នាំ | (ស្រី០១នាក់ រស់នៅឯករាជ្យ នៅក្នុងខេត្តរបស់ពួកគេ។<br>- កុមារចំនួន ០២នាក់(ស្រី០២នាក់) បានគាំទ្រលើការផ្ញើសមាហរណកម្មទៅកាន់គ្រួសារធម៌រយៈពេលខ្លី នៅរាជធានីភ្នំពេញ។<br>- កុមារចំនួន ២៤៥នាក់ (ស្រី៩៥នាក់))បានទទួលការគាំទ្រដើម្បីបន្តការសិក្សានៅសាលារដ្ឋ ក្នុងខេត្តរបស់ពួកគេ។<br>- យុវវ័យចំនួន ០៧នាក់ បាន ជួយស្វែងរកការងារឱ្យធ្វើ របង្កើតមុខរបរ ដោយខ្លួនឯង នៅខេត្តរបស់ពួកគេ ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១២។<br>- យុវវ័យចំនួន ២១នាក់ (ស្រី០៨នាក់)ត្រូវបានតាមដានលើការងារឬការចាប់ផ្តើមអាជីវកម្មផ្ទាល់ខ្លួនរបស់ពួកគេនៅក្នុងខេត្តរបស់ពួកគេ។<br>- គ្រួសាររស់នៅតាមផ្លូវចំនួន ១គ្រួសារ បានគាំទ្រឱ្យត្រឡប់ទៅស្រុកកំណើតវិញ នៅខេត្តព្រៃវែងតាមរយៈការគាំទ្រអាជីវកម្មខ្នាតតូច។ |
| **៤.៥ ដោយមានការគាំទ្រពី សង្គមអាជីវកម្មសង្គមកិច្ច (FSB), មិត្តសំឡាញ់ មានចីរភាព ៥០ %** | ចំណូលរបស់អង្គការមិត្តសំឡាញ់តាមរយៈអាជីវកម្ម:<br>ចំណាយសរុបរបស់អង្គការមិត្តសំឡាញ់:<br>និរន្តភាព: ៥០ %<br>**សិប្បកម្មតាមផ្ទះ**<br>- គ្រួសារចំនួន១២៥ នឹងចូលរួមកម្មវិធីសិប្បកម្មតាមផ្ទះ ដោយមានកុមារចំនួន ៣៧០នាក់ បានទទួលផលពីគម្រោងនេះ ក្នុង១ឆ្នាំ ។<br>- គ្រួសារសិប្បកម្មតាមផ្ទះថ្មីចំនួន ២៥ គ្រួសារ និងអាណាព្យាបាលចំនួន ១២៥នាក់ នឹងទទួលបានការបណ្តុះបណ្តាលនៅមជ្ឈមណ្ឌលផលិតកម្ម (ប្រេឡអ៊ិនធើណា | ចំណូលរបស់អង្គការមិត្តសំឡាញ់តាមរយៈអាជីវកម្ម: ៥៤២,៥២៨.៦២ ដុល្លារ<br>ចំណាយសរុបរបស់អង្គការមិត្តសំឡាញ់: ៣៦៩,២៥៦.១០ ដុល្លារ<br>និរន្តភាព: ៧១.១២%<br>**សិប្បកម្មតាមផ្ទះ**<br>- មាតាបិតាសិស្សចំនួន ៨៨ បានចូលរួមកម្មវិធីសិប្បកម្មតាមផ្ទះ ដោយមានកុមារចំនួន ៣០៥នាក់(ស្រី១០៥នាក់)បានទទួលផលពីគម្រោងនេះ។<br>- មានគ្រួសារសិប្បកម្មតាមផ្ទះថ្មីចំនួន ០១ គ្រួសារ និងអាណាព្យាបាល ៨៨នាក់ បានចូលរួមការបណ្តុះបណ្តាលនៅមជ្ឈមណ្ឌលផលិតកម្ម (ប្រេឡអ៊ិនធើណា សិនណល |

| | | |
|---|---|---|
| | សិទណាលនិងអណ្ដូង)<br>- យុវវ័យចំនួន ២០នាក់ នឹងទទួលបានគាំទ្រឱ្យមានការងារតាមរយៈអាជីវកម្មសង្គមកិច្ច (មិត្តសំឡាញ់និងប្រេន្ទអ៊ិនធើណាសិនណល)<br>- ការលក់ផលិតផលពីសិប្បកម្មតាមផ្ទះក្នុងហាងលក់ទំនិញប្រេន្ទ អេន ស្តាហ្វ ហាងទូចម្ទូច ការលក់ក្នុងស្រុក និងអន្តរជាតិ នឹងបង្កើនប្រាក់ចំណូលចំនួន ៣០៧,០០០ ដុល្លារ ដែលមានកំណើនចំនួន៥០ %<br>**មជ្ឈមណ្ឌលផលិតកម្ម**<br>- អាណាព្យាបាលចំនួន ៧០នាក់ កំពុងទទួលបានការបណ្តុះបណ្តាលជំនាញសិប្បកម្មតាមផ្ទះ និងអាជីវកម្មខ្នាតតូច<br>- អាណាព្យាបាលចំនួន ១៥ នាក់ កំពុងធ្វើការបោះពុម្ព<br>- **ក្រុមអាជីវកម្មខ្នាតតូច** កំពុងផ្តល់ការបណ្តុះបណ្តាល និងគាំទ្រគ្រួសារចំនួន ១៥០ (រួមបញ្ចូល៤០ គ្រួសារថ្មី) ដើម្បីបង្កើតអាជីវកម្មផ្ទាល់ខ្លួន និងបង្កើនប្រាក់ចំណូលរបស់ពួកគេ ដោយមានកុមារចំនួន ៥៨០នាក់ដែលនឹងទទួលបានផលពីអាជីវកម្មនេះ<br><br>- **កាហ្វេមិត្តសំឡាញ់** បង្កើតប្រាក់ចំណូលចំនួន ៣០,០០០ដុល្លារ ក្នុង១ ឆ្នាំ<br>- **ផលិតផលមិត្តសំឡាញ់** (សៀវភៅរៀនធ្វើម្ហូបប្រេន្ទ)នឹងអាចរកចំណូលបានចំនួន ៤៥,០០០ដុល្លារ ក្នុងមួយឆ្នាំ (កើនឡើង៥% )និងប្រាក់ចំណេញចំនួន ២៥, ០០០ ក្នុងមួយឆ្នាំ<br>- **ជំនាញវិជ្ជាជីវៈទាំងអស់** ដើរតួនាទីជាអាជីវកម្មសង្គមកិច្ច | និងអណ្ដូង)<br>- យុវវ័យចំនួន ០៨នាក់ បានទទួលការគាំទ្រឱ្យមានការងារតាមរយៈគម្រោងធុរកិច្ចសង្គម (មិត្តសំឡាញ់និងប្រេន្ទអ៊ិនធើណាសិនណល)។<br>- ការលក់ផលិតផលសិប្បកម្មតាមផ្ទះក្នុង ហាងលក់ទំនិញប្រេន្ទអេនស្តាហ្វ ហាងទូចម្ទូច ការលក់ក្នុងស្រុក និងអន្តរជាតិ កំពុងបង្កើនប្រាក់ចំណូល បានចំនួន ៧៦,៧៦២ដុល្លារនិងប្រាក់ចំណេញ៣៣,១៥១.៦៨ល្លារ។<br>**មជ្ឈមណ្ឌលផលិតកម្ម**<br>- អាណាព្យាបាលចំនួន ៥០នាក់ បានទទួលការបណ្តុះបណ្តាលជំនាញសិប្បកម្មតាមផ្ទះ និងអាជីវកម្មខ្នាតតូច។<br>- អាណាព្យាបាលចំនួន ៤នាក់ បំរើការងារលើការបោះពុម្ព<br>- **ក្រុមអាជីវកម្មខ្នាតតូច** កំពុងផ្តល់ការបណ្តុះបណ្តាល និងគាំទ្រគ្រួសារចំនួន ១១៣ (រួមបញ្ចូល០៣ គ្រួសារថ្មី) ដើម្បីបង្កើតអាជីវកម្មផ្ទាល់ខ្លួន និងបង្កើនប្រាក់ចំណូលរបស់ពួកគេ ដោយមានកុមារ ៣៧៧នាក់ (ស្រី២០៧ នាក់) បានទទួលផលពីអាជីវកម្មនេះ។<br>- **កាហ្វេមិត្តសំឡាញ់** បង្កើតប្រាក់ចំណូលចំនួន ១២,៥៤២.២២ដុល្លារ និងប្រាក់ចំណេញ ៤៧៨.៧៤ ដុល្លារ ។<br>- **ផលិតផលមិត្តសំឡាញ់** (សៀវភៅរៀនធ្វើម្ហូបប្រេន្ទ)អាចរកចំណូលបានចំនួន ១៥,១១១.៦៩ ដុល្លារនិងប្រាក់ចំណេញចំនួន ១៥,១១១.៦៩ ដុល្លារ។<br>- **ជំនាញវិជ្ជាជីវៈ** បានក្លាយជាធុរកិច្ចរួមមាន: ថ្នាក់កាត់ដេរ ថ្នាក់ជួសជុលម៉ូតូ/ឡាន ថ្នាក់អគ្គិសនី ថ្នាក់អេឡិចត្រូនិច ថ្នាក់ផ្សារដែក ថ្នាក់ចុងភៅ ថ្នាក់កាត់សក់ |

| | | |
|---|---|---|
| | - **កន្លែងធ្វើក្រឡា** ស្ថិតនៅខាងក្នុង ហាងប្រេនឡអនស្កាស់ នៅលើផ្លូវ ១៣ ជិតភោជនីយដ្ឋានប្រេនឡ<br>- **វិជ្ជាជីវៈភោជនីយដ្ឋាន** ចំនួន២ (សូមមើល សកម្មភាព ៤.៣) )បានចូលរួមទៅក្នុងអាជីវកម្មសង្គមកិច្ច និងទទួលបានប្រាក់ចំណូល ១,១៥៤,000 ដុល្លារក្នុង ១ឆ្នាំ ដោយមានប្រាក់ចំណេញ ៣៣៨,000ដុល្លារ ក្នុង១ឆ្នាំ។ ភោជនីយដ្ឋានចំនួន ២ នឹងមាននិរន្តរភាពរហូតដល់១00% | និងថ្នាក់កែសម្ផស្ស បង្កើតបានប្រាក់ចំណូល ៩,២៣៣.២៦ ដុល្លារ ជាមួយប្រាក់ចំណេញ ២,៤១២៦៨ ដុល្លារ។<br>- **កន្លែងធ្វើក្រឡា** បង្កើតបានប្រាក់ចំណូលចំនួន ៣,៥៥២ដុល្លារ និងខាតចំនួន –៥២៧.៨១ ដុល្លារ។<br>- **វិជ្ជាជីវៈភោជនីយដ្ឋាន** ចំនួន២ (សូមមើល សកម្មភាព៤.៣)បានចូលរួមក្នុងអាជីវកម្មសង្គមកិច្ច ទទួលបានប្រាក់ចំណូល ៤២៥,៣២៦.៣៥ ដុល្លារ ដោយមានប្រាក់ចំណេញ១២២,៦៤៥.៥៤ ដុល្លារ។<br>**ភោជនីយដ្ឋានប្រេនឡ:** ២២២,១២៩.៥៨ដុល្លារ ប្រាក់ចំណូល និងប្រាក់ចំណេញ: ៧១,៧0៧.៤៥ ដុល្លារ<br>**ភោជនីយដ្ឋានរំដេង:** ២0៣,១៩៦.៧៧ដុល្លារ ប្រាក់ចំណូល និងប្រាក់ចំណេញ ៥0,៩៣៨.0៩ ដុល្លារ។<br>**ព្រឹត្តិការណ៍និងកំណត់សម្គាល់ពិសេស**<br>- មណ្ឌលសំចតនៅក្នុងមណ្ឌលសិប្បកម្មតាមផ្ទះបានផ្លាស់ទៅមណ្ឌលសំចតថ្មី នៅថ្ងៃទី ១២ ខែមីនា ឆ្នាំ២0១២។<br>- ក្រុមសិប្បកម្មតាមផ្ទះបានបង្កើតផលិតផលថ្មីចំនួន ៥មុខបន្ថែមទៀតនៅក្នុងត្រីមាសនេះ។<br>- បានផ្គត់ផ្គង់ផលិតផលសិប្បកម្មតាមផ្ទះទាន,ពេលដល់ហាងថ្មីនៃអង្គការប្រេនឡអ៊ិនធើណាសិនណាល នៅសណ្ឋាគារអ៊ិនធើខន។<br>- បានធ្វើការតាមដានលើគ្រួសារអាជីវកម្មខ្នាតតូចនៅរាជធានីភ្នំពេញចំនួន ៦៤ ដង។<br>- បានវាយតម្លៃសេដ្ឋកិច្ចគ្រួសារចំនួន 0៣ គ្រួសារ ដើម្បីផ្តល់ការបណ្តុះបណ្តាលអាជីវ |

| | | |
|---|---|---|
| | | កម្មជាមូលដ្ឋានកំរិត២សម្រាប់ដំណើការអាជីវកម្មខ្នាតតូច។<br>- គ្រួសារអាជីវកម្មខ្នាតតូចចំនួន ២ គ្រួសារ បានចូលរួមលក់ នៅក្នុងកម្មវិធីហាន់ហ្វែរ ដែលទទួលបានប្រាក់ចំណូលគួរសម នាថ្ងៃទី ២១ ខែ មករា ឆ្នាំ២០១២ ។<br>- ក្រុមអាជីវកម្មសង្គម បានចូលរួមតាំងផលិតផល នៅក្នុងកម្មវិធី រាត្រីពណ៌បៃតង និងការតាំងពិព័រណ៍របស់អង្គការម៉ៃឌីខាំ។ |
| **៥. ក្រុមឯកទេស ៨ក្រុមកំពុងផ្តល់ការជួយគាំទ្រកម្មវិធីនៅត្រឹមឆ្នាំ ២០១២** | | |
| **៥.១ ក្រុមឯកទេសលើការ ការពារកុមារ** | **លទ្ធផលរំពឹងទុក:**<br>- របាយការណ៍ស្តីពីការរំលោភបំពាន ១00ករណីនឹងត្រូវបានបំពេញ<br>**ការតាមដាន វាយតម្លៃ និងស្រាវជ្រាវ**<br>- ការវាយតម្លៃគោលការណ៍ការពារកុមារនៅក្នុងមណ្ឌលសំចត មជ្ឈមណ្ឌលអប់រំ មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវះ និងគ្រប់មណ្ឌលស្នាក់នៅបណ្តោះអាសន្ន ទាំងអស់<br>- ចងក្រងរបាយការណ៍សម្រាប់មិត្តសំឡាញ់ ម្ចាស់ជំនួយ និង រដ្ឋាភិបាល<br>- រៀបចំការស្ទង់មតិលើការស្នាក់នៅរបស់កុមារដែលស្នាក់នៅមណ្ឌលស្នាក់នៅបណ្តោះអាសន្នរបស់អង្គការមិត្តសំឡាញ់ រៀងរាល់៣ខែម្តង<br>**គាំទ្របច្ចេកទេស**<br>- បុគ្គលិក១00% នឹងទទួលការបណ្តុះបណ្តាល និងរំលឹកឡើងវិញលើគោលការណ៍ការពារសិទ្ធិកុមារ<br>- ការបោះឆ្នោតជ្រើសរើសតំណាងកុមានឹងរៀបចំជារៀងរាល់៦ខែ ក្នុងឆ្នាំ | **លទ្ធផលសំរេចបាន:**<br>- របាយការណ៍ស្តីពីការរំលោភបំពាន ២៦ករណី បានបំពេញ និងបញ្ជូនទៅអាជ្ញាធរ ដើម្បីអន្តគមន៍។<br>**ការតាមដាន វាយតម្លៃ និងស្រាវជ្រាវ**<br>- អ្នកឯកទេសសុវត្ថិភាពកុមារ បានចូលរួមការប្រជុំក្រុមចំនួន ១២ដង ជាមួយកុមារ/យុវវ័យនៅមណ្ឌលស្នាក់នៅទាំងអស់ ស្តីពីបទបញ្ជាផ្ទៃក្នុង សិទ្ធិកុមារ លើកករណីសិក្សាមួយចំនួន និងការចែករំលែកព័ត៌មាន។<br>- បានចងក្រងរបាយការណ៍ប្រចាំត្រីមាសជូនមិត្តសំឡាញ់ ។<br>- បានរៀបចំការសម្ភាសន៍ប្រចាំត្រីមាស ស្តីពីសេវាកម្មរបស់អង្គការមិត្តសំឡាញ់ ជាមួយកុមារ/យុវវ័យចំនួន ២៨នាក់ កំពុងស្នាក់នៅមណ្ឌលស្នាក់នៅបណ្តោះអាសន្នទាំង៣ និងមណ្ឌលបន្ទាបគ្រឿងញៀន។ |

| | | |
|---|---|---|
| | **ឧបករណ៍**<br>- នឹងធ្វើបច្ចុប្បន្នភាពនិងអនុវត្តគោលការណ៍ការពារសិទ្ធិកុមារ<br>- គោលការណ៍ការពារសិទ្ធិកុមារនឹងដាក់បង្ហាញនៅគ្រប់មណ្ឌលទាំងអស់<br>- ធានាថាឧបករណ៍ទាំងអស់មាននៅក្នុងមណ្ឌលនីមួយៗ | **គាំទ្របច្ចេកទេស**<br>- បុគ្គលិកតាមផ្ទល់ចំនួន ១២១នាក់ បានទទួលវគ្គរំលឹកឡើងវិញស្តីពីគោលការណ៍ការពារសិទ្ធិកុមារ។<br>- បានចុះមូលដ្ឋានចំនួន ៦១ ដង នៅមណ្ឌលស្នាក់នៅបណ្តោះអាសន្ន មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ មជ្ឈមណ្ឌលអប់រំ និងមណ្ឌលសំចតទាំងអស់ ដើម្បីពង្រឹងដំណើរការនៃការអនុវត្តន៍គោលការណ៍ការពារសិទ្ធិកុមារ និងធានាសុវត្ថិភាពដល់កុមារ។<br>**ឧបករណ៍**<br>- បានធ្វើបច្ចុប្បន្នភាពលើបទបញ្ជាផ្ទៃក្នុងសម្រាប់មជ្ឈមណ្ឌលអប់រំ តាមរយៈការចូលរួមពីកុមារនិងយុវវ័យ។<br>- សម្ភារៈគោលការណ៍ការពារកុមារ និងតារាងផល់ព័ត៌ នៃការការពារសិទ្ធិកុមារ បានបិទនៅគ្រប់មណ្ឌលទាំងអស់។<br>**ព្រឹត្តិការណ៍និងកំណត់សម្គាល់ពិសេស**<br>- មន្ទីរសង្គមកិច្ច អតីត យុទ្ធជន និងយុវនីតិសម្បទារាជធានីភ្នំពេញ បានបញ្ជូនកុមារចំនួន ៣០នាក់ មកអង្គការមិត្តសំឡាញ់ក្នុងកិច្ចប្រជុំអាស៊ាន។<br>- បានចូលរួមសិក្ខាសាលស្តីពីការវាយតម្លៃអង្គការក្រៅរដ្ឋាភិបាលដែលបានដាក់ពាក្យស្នើសុំវិញាបនបត្រអង្គការសុវត្ថិភាពកុមារ នៅនាយកដ្ឋានសុខុមាលភាពកុមារនៃក្រសួងសង្គមកិច្ច អតីត យុទ្ធជន និងយុវនីតិសម្បទា នាថ្ងៃទី ១១-១២ខែ មករា ឆ្នាំ២០១២។<br>- បានចូលរួមកិច្ចប្រជុំសមាជិកគណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាល ដើម្បី |

| | | |
|---|---|---|
| | | សិទ្ធិកុមារ ស្តីពីស្ថានីសិទសង្គមស៊ីវិលអាស៊ាន/វេទិកាប្រជាពលរដ្ឋអាស៊ាន ឆ្នាំ ២០១២នាថ្ងៃទី ១៥ ខែមីនា ឆ្នាំ២០១២។<br>- បានចូលរួមប្រជុំសមាជិកអង្គការ ECPAT ស្តីពីបទបង្ហាញពីគម្រោង របស់អង្គការនីមួយសម្រាប់ឆ្នាំ២០១២ នាថ្ងៃទី ១៦ ខែមីនា ឆ្នាំ២០១២។<br>- បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិស្តីពីការពារនាសិទ្ធិកុមារ ដើម្បីដាក់បញ្ចូលទៅក្នុង របៀបវារៈនៃកិច្ចប្រជុំអាស៊ាន រៀបចំដោយអ គណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាល ដើម្បីសិទ្ធិកុមារ និងអង្គការផ្លែនអន្តរ ជាតិ នាថ្ងៃទី ២៥ ខែមីនា ឆ្នាំ២០១២។ |
| **៥. ២ ក្រុមឯកទេសវេជ្ជសាស្ត្រ** | **លទ្ធផលរំពឹងទុក:**<br>- សេវាព្យាបាលនិងសង្គ្រោះបឋមចំនួន ៨៥,000 នឹងផ្តល់ជូនកុមារ/យុវវ័យ ក្នុងនោះមានសេវាសម្រាប់អ្នកប្រើប្រាស់គ្រឿងញៀន/អ្នកប្រើប្រាស់គ្រឿងញៀនដោយចាក់ចំនួន ២៣,000 សេវា<br>- កុមារ/យុវវ័យចំនួន ៨៥0នាក់នឹងបញ្ជូនទៅនៅមន្ទីរពេទ្យ<br>- កុមារ/យុវវ័យផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍ចំនួន ១0នាក់ នឹងទទួលបានការព្យាបាលនៅមន្ទីរពេទ្យ<br>- អាណាព្យាបាលដែលផ្ទុក មេរោគអេដស៍ និងជំងឺអេដស៍ចំនួន ៣0នាក់ នឹងទទួលបានការព្យាបាលនៅមន្ទីរពេទ្យ<br>- កុមារ/យុវវ័យចំនួន ៣00នាក់នឹងទទួលការព្យាបាលជំងឺកាមរោគ<br>- អាណាព្យាបាលចំនួន ៩0នាក់នឹងទទួលការព្យាបាលជំងឺកាមរោគ | **លទ្ធផលសំរេចបាន:**<br>- សេវាព្យាបាលនិងសង្គ្រោះបឋមចំនួន ២៤,៨៤៥ បានផ្តល់ជូនកុមារ/យុវវ័យ ក្នុងនោះមានសេវាសម្រាប់អ្នកប្រើប្រាស់គ្រឿងញៀន/អ្នកប្រើប្រាស់គ្រឿងញៀនដោយចាក់ចំនួន ៧, 0២៩ សេវា ។<br>- កុមារ/យុវវ័យចំនួន ២១៥នាក់ បានបញ្ជូនទៅនៅមន្ទីរពេទ្យ<br>- កុមារផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍ចំនួន 0១នាក់ បានទទួលការព្យាបាលនៅមន្ទីរពេទ្យ ។<br>- អាណាព្យាបាលដែលផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍ចំនួន ១៣នាក់ បានទទួលការព្យាបាលនៅមន្ទីរពេទ្យ ។<br>- កុមារ/យុវវ័យចំនួន ៧៨នាក់ បានទទួលការព្យាបាលជំងឺកាមរោគ<br>- អាណាព្យាបាលចំនួន ២៣នាក់ បានទទួលការព្យាបាលជំងឺកាមរោគ |

| | | |
|---|---|---|
| | **ការតាមដាន វាយតម្លៃ និងស្រាវជ្រាវ**<br>- ប្រព័ន្ធត្រួតពិនិត្យនិងប្រមូលទិន្នន័យគឺជាសូចនាករលក្ខណៈស្តង់ដា នៃកម្មវិធីប្រេនឡូ អ៊ិនធើណាសិនណលសម្រាប់សកម្មភាពសុខាភិបាល<br>- ការវាយតម្លៃលើការថែរក្សាផ្នែកសុខភាពនៅក្នុងគម្រោងទាំងអស់មានកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទជាមួយអ្នកឯកទេសហ៊ីវ/ អេដស៍ក្នុងរយៈពេល១ឆ្នាំ<br>- ផងក្រងរបាយការណ៍សម្រាប់មិត្តសំឡាញ់ ម្ចាស់ជំនួយ និងរដ្ឋាភិបាល<br>**គាំទ្របច្ចេកទេស**<br>- បុគ្គលិកវេជ្ជសាស្ត្រទាំងអស់នឹងទទួលបានការបណ្តុះបណ្តាលយ៉ាងទៀងទាត់<br>- ជំនួយបច្ចេកទេស នឹងផ្តល់ជារៀងរាល់សប្តាហ៍តាមរយៈការងារនៅតាមមូលដ្ឋានជាមួយក្រុមទាំងអស់<br>- ពង្រឹងកិច្ចសហការរវាងបុគ្គលិកសុខាភិបាលនិងអ្នកគ្រប់គ្រងករណី<br>- ពិនិត្យ ឡើងវិញនិងបញ្ជាទិញសម្ភារៈវេជ្ជសាស្ត្រតាមតម្រូវការរបស់ក្រុមការងារ<br>**ឧបករណ៍**<br>- សៀវភៅណែនាំនឹងរៀបចំអនុវត្តនិងធ្វើបច្ចុប្បន្នភាពជាទៀងទាត់<br>**ដៃគូ**<br>- បង្កើត ប្រើប្រាស់ និងធ្វើបច្ចុប្បន្នភាពបញ្ជីសេវាកម្មជារៀងរាល់ឆ្នាំ និងចែករំលែកជាមួយក្រុមទាំងអស់<br>- បុគ្គលិកអង្គការដៃគូចំនួន ៣៥នាក់នឹងត្រូវបានស្វែងរក និងបណ្តុះណ្តាលក្នុងមួយឆ្នាំ<br>- ប្រសិទ្ធិភាពនៃកិច្ចសហការជាមួយរដ្ឋាភិបាល | **ការតាមដាន វាយតម្លៃ និងស្រាវជ្រាវ**<br>- តាមរយៈការចុះមូលដ្ឋាន និងតាមដានពីអ្នកឯកទេស គ្លីនិកទាំងអស់មាន អនាម័យល្អបន្ទប់ស្អាត ទម្រង់អង្កេតរបស់កុមារត្រូវបានបំពេញ និងកន្លែងទុកថ្នាំត្រូវបានរៀបចំយ៉ាងរៀបរាយ។<br>- ការត្រួតពិនិត្យសុខភាពកុមារ/យុវវ័យចំនួន ៧១ ដងបានធ្វើជាទៀងទាត់នៅពេលកុមារ/ យុវវ័យចាប់ផ្តើមចូលរៀននៅអង្គការមិត្តសំឡាញ់ និងមុនពេលបញ្ជូនទៅគ្រួសារ ឬប្រកបមុខរបរ។<br>- បានផងក្រងរបាយការណ៍ប្រចាំត្រីមាសដើម្បីផ្ញើរជូនមិត្តសំឡាញ់។<br>- បានធ្វើបច្ចុប្បន្នភាពលើទម្រង់នៃការពិនិត្យសុខភាពអ្នកជំងឺ សម្រាប់បញ្ជូនទៅមណ្ឌលបន្សាប និងស្ថានីពិសម្បទានៅផ្ទះបៃតង។<br>- បានរៀបចំការស្ទង់សំណួរសម្រាប់ធ្វើវាយតម្លៃលើសេវាសុខភាពនៃអង្គការមិត្តសំឡាញ់ជាមួយបុគ្គលិក ពេទ្យ ដោយមានកិច្ចសហការជាមួយអ្នកស្ម័គ្រចិត្តនៃអង្គការប្រេនឡូ អ៊ិនធើណាសិនណល។<br>**គាំទ្របច្ចេកទេស**<br>- បានគាំទ្រករណីពិសេសចំនួន ៣ ករណី ។ ករណីកុមារ ១នាក់ត្រូវបានគេបោះបង់ បានបញ្ជូនទៅព្យាបាលផ្នែកស្មារតីនៅមន្ទីរពេទ្យជ័យជំនះ និង យុវវ័យប្រើប្រាស់គ្រឿងញៀនហើមជើង ១នាក់ និងយុវវ័យរះកាត់ដៃ ១ទៀត បានបញ្ជូនទៅមន្ទីរពេទ្យកាល់ម៉ែត និងមជ្ឈមណ្ឌលស្ថានីពិសម្បទាគៀនឃ្លាំង ។<br>- បានចុះមូលដ្ឋានចំនួន ៥៨ដង ក្នុង៥តំបន់ រួមបញ្ចូលទាំងមណ្ឌលស្នាក់នៅបណ្តោះអាសន្ន ផ្ទះបៃតង និងមណ្ឌលសំចោចល័តទាំង ២ផង ដើម្បីជួយអ្នកគ្រប់គ្រង |

| | | |
|---|---|---|
| | | ករណីនិងប្រធានតំបន់ ក្នុងការគាំទ្រផ្នែកសុខ ភាពដល់កុមារ/យុវវ័យ និងគ្រួសារតាមតំបន់គោលដៅ។<br>**ឧបករណ៍**<br>- គោលការណ៍ណែនាំលើសេវាការព្យាបាលបឋម បានឯកភាពពីនាយកកម្មវិធីព្រមទាំងបានបណ្តុះបណ្តាលដល់បុគ្គលិកពេទ្យទាំងអស់ និងដាក់អោយអនុវត្តក្នុងត្រីមាសនេះ។<br>**ដៃគូ**<br>- បានទស្សនកិច្ចនៅមន្ទីរពេទ្យជ័យជំនះ ដើម្បីដាក់បញ្ចូលនៅទៅក្នុងបញ្ជីសេវាកម្មដោយមានកិច្ចសហការពីអង្គការប្រេហ្វអ៊ិនធើណាសិនណល។<br>ការប្រជុំនិងកិច្ចសហការជាមួយរដ្ឋាភិបាល/អង្គការដៃគូ:<br>- បានសហការជាមួយវេជ្ជបណ្ឌិត នៅមជ្ឈមណ្ឌលស្ថានីតិសម្បទាគៀនឃ្លាំង មន្ទីរពេទ្យកាល់ម៉ែត មន្ទីរពេទ្យគន្ធបុប្ផា មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ដើម្បីគាំទ្រនិងព្យាបាលកុមារនិងយុវវ័យដែលឥតបង់ថ្លៃ។<br>- បានចូលរួមការប្រជុំប្រចាំខែជាមួយអង្គការម៉េឌីខាំ និងមន្ទីរសុខាភិបាលពាក់ព័ន្ធទៅនឹងបញ្ហាផ្នែកសុខភាព ជាមួយអង្គការដៃគូផ្សេងទៀត ។<br>- កុមារនៅមជ្ឈមណ្ឌលអប់រំចំនួន ១២៦ នាក់(ស្រី៥១ នាក់) បានគាំទ្រលើការព្យាបាល និងថែទាំសុខភាពមាត់ធ្មេញពីអង្គការ One 2 One នៅមន្ទីរពេទ្យព្រះកុមារ។<br>**ព្រឹត្តិការណ៍និងកំណត់សម្គាល់ពិសេស**<br>- ឆ្នាំនេះដែរមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត នៅបន្តការចុះតម្លៃ ២០ % និងពេទ្យ |

| | | |
|---|---|---|
| | | ក្រុង ១០% ចំពោះការព្យាបាលអតិថិជនរបស់អង្គការមិត្តសំឡាញ់។<br>- គ្រួសារដែលរស់នៅជាមួយមេរោគអេដស៍ និងជម្ងឺអេដស៍ចំនួន ៣០ គ្រួសារ បានទទួលព័ត៌មានពីការថែរក្សាសុខភាព ពីអ្នកឯកទេស វេជ្ជសាស្ត្រ នៅសហគមន៍អណ្តូង និងតំបន់វត្តភ្នំ។ |
| **៥.៣ ក្រុមឯកទេសមេរោគអេដស៍/ជម្ងឺអេដស៍** | **លទ្ធផលរំពឹងទុកៈ**<br>- កុមារចំនួន ២៥០នាក់ នឹងបញ្ជូនទៅធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសំងាត់<br>- អាណាព្យាបាលចំនួន ៣៥០នាក់ នឹងបានចូលរួមក្រុមគាំទ្រផ្លូវចិត្ត(EGS ) គិតជាចំនួនសេវាស្មើ៤,៥០០<br>- កុមារ/យុវវ័យចំនួន ៥០នាក់ នឹងទទួលថ្នាំឡេជីវិត(ARV) និងការព្យាបាលជម្ងឺឱកាសនិយម(OI)<br>- កុមារ/យុវវ័យចំនួន ៥០០នាក់ ដែលឆ្លងនិងរងផលប៉ះពាល់មេរោគអេដស៍/ជម្ងឺអេដស៍នឹងទទួលបានសេវានៅមិត្តសំឡាញ់ ឬតាមរយៈមិត្តសំឡាញ់<br>- អាណាព្យាបាលចំនួន ៣០០នាក់ ដែលទទួលរងផលប៉ះពាល់ នឹងទទួលបានសេវាសង្គមនៅមិត្តសំឡាញ់ ឬតាមរយៈមិត្តសំឡាញ់<br><br>**ការតាមដាន វាយតម្លៃ និងស្រាវជ្រាវ**<br>- ប្រព័ន្ធនៃការត្រួតពិនិត្យនិងប្រមូលទិន្នន័យ គឺជាសូចនាករលក្ខណៈស្តង់ដានៃកម្មវិធីប្រព្រឹត្តអ៊ិនធើណាសិនណលសម្រាប់សកម្មភាព ដែលពាក់ព័ន្ធមេរោគអេដស៍/ជម្ងឺអេដស៍ (បំណិនជីវិត សមាហរណកម្ម ការគាំទ្រគ្រួសារ និងទទួលបាន ការព្យាបាល) | **លទ្ធផលសំរេចបានៈ**<br>- កុមារចំនួន ៥០នាក់ បានបញ្ជូនទៅធ្វើតេស្តឈាមរកមេរោគ អេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសំងាត់ ។<br>- អាណាព្យាបាលចំនួន ២៨៦នាក់ បានចូលរួមក្រុមគាំទ្រផ្លូវចិត្ត(EGS ) ប្រចាំសប្តាហ៍ ស្មើនឹងសេវាចំនួន ១,១៧២<br>- កុមារ/យុវវ័យចំនួន ៤៨នាក់ បានទទួលថ្នាំឡេជីវិត(ARV) និងការព្យាបាលជម្ងឺឱកាសនិយម(OI) ជារៀងរាល់សប្តាហ៍។<br>- កុមារ/យុវវ័យចំនួន ៥៣១នាក់ ដែលឆ្លងនិងរងផលប៉ះពាល់មេរោគអេដស៍/ជម្ងឺអេដស៍ បានទទួលសេវានៅមិត្តសំឡាញ់ ឬតាមរយៈមិត្តសំឡាញ់ ។<br>- អាណាព្យាបាលចំនួន ២៤៣នាក់ ដែលទទួលរងផលប៉ះពាល់ បានទទួលសេវាសង្គមរួមមានៈ អាហារ ការជួលផ្ទះ និងការគាំទ្រ អាជីវកម្មខ្នាតតូច នៅអង្គការមិត្តសំឡាញ់ ។<br>**ការតាមដាន វាយតម្លៃ និងស្រាវជ្រាវ**<br>- បានចុះមូលដ្ឋានចំនួន ២៥ដង ក្នុង៥តំបន់ នៃក្រុមតាមដានផ្ទាល់ផ្ទះបៃតង មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ និងអប់រំ មណ្ឌលសំចតចល័ត ដើម្បីគាំទ្រអ្នកគ្រប់គ្រង់ករណី និងអ្នកសម្របសម្រួលក្រុមគាំទ្រផ្លូវចិត្តនៅក្នុងតំបន់នីមួយរៀងរាល់ |

| | | |
|---|---|---|
| | - ការវាយតម្លៃលើសកម្មភាព ដែលពាក់ព័ន្ធនឹងមេរោគអេដស៍/ជំងឺអេដស៍ (បំណិនជីវិត សមាហរណកម្ម ការគាំទ្រគ្រួសារ និងការទទួលបានការព្យាបាល)<br>- ផងក្រងរបាយការណ៍សម្រាប់មិត្តសំឡាញ់ ម្ចាស់ជំនួយ និងរដ្ឋាភិបាល<br>- រៀបចំការស្រាវជ្រាវមួយលើគម្រោងមេរោគអេដស៍និងជំងឺអេដស៍នៅចុង ឆ្នាំ ២០១២<br>**ការគាំទ្របច្ចេកទេស**<br>- បុគ្គលិក១០០ % នឹងទទួលបានការបណ្តុះបណ្តាលស្តីពីការយល់ដឹងច្បាស់លាស់ពីមេរោគអេដស៍/ជំងឺអេដស៍ (ថ្នាំទ្បាជីវិត ការបង្ការការឆ្លងមេរោគអេដស៍ពី ម្តាយទៅកូន ការធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសំងាត់។ ល។<br>- នឹងផ្តល់ការគាំទ្របច្ចេកទេសជារៀងរាល់សប្តាហ៍ តាមរយៈការងារនៅមូលដ្ឋាន ជាមួយក្រុមតាមថ្នល់និងសមាហរណកម្ម<br><br>**ឧបករណ៍**<br>- សម្ភារៈអប់រំលើមេរោគអេដស៍/ជំងឺអេដស៍នឹងត្រួតពិនិត្យ និងធ្វើបច្ចុប្បន្នភាពជាប្រចាំ<br>- សៀវភៅជីវប្រវត្តិនឹងត្រូវធ្វើបច្ចុប្បន្នភាពនិងអនុវត្ត<br>- ទម្រង់បន្ថែមនៃការគ្រប់គ្រងករណី នឹងត្រូវបានបង្កើត អនុវត្ត និងធ្វើបច្ចុប្បន្នភាពជាប្រចាំ<br>- សៀវភៅណែនាំស្តីពីការគាំទ្រផ្លូវចិត្ត និងការធ្វើការជាមួយគ្រួសារ ដែលរស់នៅ ជាមួយមេរោគអេដស៍និងជំងឺអេដស៍នឹងរៀបចំអនុវត្ត និងធ្វើបច្ចុប្បន្នភាពជាទៀងទាត់<br>**ដៃគូ**<br>- បង្កើត ប្រើប្រាស់ និងធ្វើបច្ចុប្បន្នភាពបញ្ជីសេវាកម្មជារៀងរាល់ឆ្នាំ និងចែករំលែកដល់ក្រុមទាំងអស់ | សប្តាហ៍។<br>- បានផងក្ររបាយការណ៍ប្រចាំខែ និងត្រីមាសជូនមិត្តសំឡាញ់ ។<br><br><br>**គាំទ្របច្ចេកទេស**<br>- បានសហការជាមួយក្រុមការងារប្រូឡូអ៊ិនធើណាសិនណល និងអង្គការឱសថការីគ្មានព្រំដែន ដើម្បីវគ្គបណ្តុះបណ្តាលស្តីពីចំណេះដឹងមេរោគអេដស៍/ជំងឺអេដស៍ ការកាត់បន្ថយការឆ្លងពីម្តាយទៅទារក និងជំងឺរបេង ដល់បុគ្គលិកសង្គម។<br>- បានចូលរួមប្រជុំប្រចាំខែជាមួយអ្នកសម្របសម្រួលក្រុមគាំទ្រផ្លូវចិត្តដើម្បីស្វែងរកប្រធានបទ បញ្ហាប្រឈម និងដំណោះស្រាយ ដើម្បីឆ្លើយតបដល់ពួកគេ។<br>- បានចុះអង្កេតក្រុមគាំទ្រផ្លូវចិត្តចំនួន ២៤ដង នៅគ្រប់តំបន់ទាំងអស់នៃក្រុមតាមថ្នល់ដើម្បីស្វែងយល់ពីការកើនឡើងពីស្ថិតិនៃអ្នកចូលរួមរបស់ក្រុមគាំទ្រផ្លូវចិត្ត។<br>- បុគ្គលិកមកពីក្រុមតាមថ្នល់ចំនួន ១៩នាក់ (ស្រី១២នាក់) បានទទួលវគ្គបណ្តុះបណ្តាលស្តីពី ការកាត់បន្ថយការឆ្លងពីម្តាយទៅកូន និងជំងឺរបេង ពីគ្រូឧទេសមកពីឱសថការីគ្មានព្រំដែន។<br>**ឧបករណ៍**<br>- គោលការណ៍ណែនាំលើការគ្រប់គ្រងករណីមេរោគអេស៍/ជំងឺអេស៍ និងទម្រង់បន្ថែមកំពុងអនុវត្តជាមួយក្រុមពាក់ព័ន្ធទាំងអស់ ចាប់តាំងពីឆ្នាំ២០១១។<br>- សម្ភារៈអប់រំ ស្តីពីការកាត់បន្ថយការឆ្លងពីម្តាយទៅកូន កំពុងធ្វើតេស្តជាមួយក្រុមគោលដៅ ហើយសម្ភារៈអប់រំនេះ នឹងបោះពុម្ពឱ្យប្រើប្រាស់នៅដើមត្រីមាស |

| | | |
|---|---|---|
| | - បុគ្គលិកអង្គការដៃគូចំនួន ៣០នាក់នឹងត្រូវបានស្វែងរក និងបណ្តុះបណ្តាល<br>- ប្រសិទ្ធិភាពនៃកិច្ចសហការជាមួយរដ្ឋាភិបាល | ទី២ក្នុងឆ្នាំ២០១២។<br>**ដៃគូ**<br>- បានទស្សនកិច្ចនៅសមាគមឥន្ទ្រទេវី អង្គការមេត្រីអន្តរជាតិ អង្គការអភិវឌ្ឍន៍ស្ត្រីកម្ពុជា ដើម្បីដាក់បញ្ចូល នៅទៅក្នុងបញ្ជីសេវាកម្ម ដោយមានកិច្ចសហការពីអង្គការប្រេន្សអុិនធើណាសិនណល។ បញ្ជីសេវាកម្មចង់ក្រងបាន ៥៨ អង្គការរហូតមកដល់ពេលនេះ។<br><u>ការប្រជុំនិងកិច្ចសហការជាមួយរដ្ឋាភិបាល/អង្គការដៃគូ:</u><br>- បានចូលរួមប្រជុំប្រចាំត្រីមាសលើទី៦០ នៃគណៈកម្មាធិការសម្របសម្រួលមេរោគអេដស៍និងជម្ងឺអេដស៍(HACC) ដើម្បីចែករំលែកព័ត៌មាន និងលើកឡើង នូវបញ្ហាជួបប្រទះ នៅសណ្ឋាគារសាន់វេ នាថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១២។<br>- បានចូលរួមកិច្ចប្រជុំពិគ្រោះយោបល់លើរបាយការណ៍មេរោគអេដស៍និង ជម្ងឺអេដស៍ថ្នាក់ជាតិនៅសណ្ឋាគារណាហ្គាវើល រៀបចំឡើងដោយគណៈកម្មាធិការសម្របសម្រួលមេរោគអេដស៍និងជម្ងឺអេដស៍នាថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ ២០១២។<br>- បានចូលរួមសិក្ខាសាលាស្តីពី មេរោគអេដស៍និង ជម្ងឺអេដស៍ ការកាត់បន្ថយការឆ្លងពីម្តាយទៅកូន និងជម្ងឺរបេងនៅអង្គការប្រេន្សអុិនធើណាសិនណល នាថ្ងៃទី ១៥/១៦/២២ ខែកុម្ភៈ ឆ្នាំ២០១២។<br>- បានចូលរួមប្រជុំពេញអង្គលើកទី១៦ ជាមួយក្រុមការងារថ្នាក់ជាតិពហុវិស័យនៃកុមារកំព្រា និងកុមារងាយរងគ្រោះ នៃក្រសួងសង្គមកិច្ច អតីត យុទ្ធជន យុវនីតិសម្បទា ស្តីពីលទ្ធផលប្រចាំត្រីមាសទី១ និងផែនការប្រចាំត្រីមាសទី២ ២០១២ នាថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១២។ |

| | | |
|---|---|---|
| ៥.៤ ក្រុមឯកទេសលើការគ្រប់គ្រងករណី | **លទ្ធផលរំពឹងទុក:**<br>**ករណីសកម្ម :**<br>- ៥,០០០ ករណីបុគ្គល<br>- ៥៥០ ករណីគ្រួសារ<br>- ២០ ករណីសហគមន៍<br>**ករណីថ្មីៗ:**<br>- ៧០០ ករណីបុគ្គល<br>- ១២០ ករណីគ្រួសារ<br>- ៤ករណីសហគមន៍<br>**ករណីដែលបានបិទ:**<br>- ៣០០ ករណីបុគ្គល<br>- ៥០ ករណីគ្រួសារ<br>- ២ករណីសហគមន៍<br>**ការតាមដាន វាយតម្លៃ និងស្រាវជ្រាវ**<br>- ប្រព័ន្ធការត្រួតពិនិត្យនិងប្រមូលទិន្នន័យ គឺជាសូចនាករលក្ខណស្តង់ដា នៃកម្មវិធីប្រូទ្យអ៊ិនធើណាសិនណលសម្រាប់ការគ្រប់គ្រងករណី<br>- ការវាយតម្លៃលើប្រព័ន្ធគ្រប់គ្រងករណី១ដង/ឆ្នាំ<br>- ផងក្រងរបាយការណ៍សម្រាប់មិត្តសំឡាញ់ ម្ចាស់ជំនួយ និងរដ្ឋាភិបាល<br>- រៀបចំការស្រាវជ្រាវមួយដង | **លទ្ធផលសំរេចបាន:**<br>**ករណីសកម្មនាត្រីមាសនេះ:**<br>- ២៦៣២ (ស្រី៩៥៤) ករណីបុគ្គល<br>- ៤៤១ ករណីគ្រួសារ<br>- ១៦ ករណីសហគមន៍<br>**ករណីថ្មីៗ នាត្រីមាសនេះ:**<br>- ១៤៣ (ស្រី៤៨)ករណីបុគ្គល<br>- ២៥ ករណីគ្រួសារ<br>- ១ ករណីសហគមន៍<br>**ករណីដែលបានបិទ នាត្រីមាសនេះ::**<br>- ៧៧ (ស្រី៣២)ករណីបុគ្គល<br>- ២៣ ករណីគ្រួសារ<br>**ការតាមដាន វាយតម្លៃ និងស្រាវជ្រាវ**<br>- បានចុះមូលដ្ឋានចំនួន ៤៩ដង ក្នុងតំបន់ទាំង៥ នៃក្រុមតាមថ្នល់ មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ និងមជ្ឈមណ្ឌលអប់រំ ដើម្បីពង្រឹងការងារគ្រប់គ្រងករណី និងដោះស្រាយករណីរបស់ពួកគេ។<br>- បានផងក្រងរបាយការណ៍ប្រចាំខែ និងត្រីមាសដើម្បីផ្ញើរជូនមិត្តសំឡាញ់។<br><br>**ការគាំទ្របច្ចេកទេស**<br>- បុគ្គលិកមិត្តសំឡាញ់ចំនួន ៤៥ នាក់(ស្រី ២០នាក់) បានទទួលការបណ្តុះបណ្តាល |

| | | |
|---|---|---|
| | **ការគាំទ្របច្ចេកទេស**<br>- បុគ្គលិកចំនួន ៨0 នាក់នឹងទទួលបានការបណ្តុះបណ្តាលស្តីពីប្រព័ន្ធគ្រប់គ្រងករណី<br>- បុគ្គលិកចំនួន ៥0 នាក់ កំពុងធ្វើការជាអ្នកគ្រប់គ្រងករណី<br>- ជំនួយការបច្ចេកទេស នឹងផ្តល់ការគាំទ្របច្ចេកទេសជារៀងរាល់សប្តាហ៍តាមរយៈការងារនៅមូលដ្ឋានជាមួយក្រុមការងារទាំងអស់<br>- កិច្ចប្រជុំស្តីពីការគ្រប់គ្រងករណី នឹងរៀបចំ និងធ្វើឡើងរៀងរាល់សប្តាហ៍នៅគ្រប់តំបន់ទាំងអស់<br>**ឧបករណ៍**<br>- សៀវភៅណែនាំស្តីពីការគ្រប់គ្រងករណី នឹងរៀបចំ អនុវត្ត និងធ្វើបច្ចុប្បន្នភាពជាទៀងទាត់<br>**ដៃគូ**<br>- បង្កើត ប្រើប្រាស់ និងធ្វើបច្ចុប្បន្នភាពបញ្ជីសេវាកម្មជារៀងរាល់ឆ្នាំ និងចែករំលែកដល់ក្រុមទាំងអស់<br>- បុគ្គលិកអង្គការដៃគូ ៤0 នាក់នឹងត្រូវបានស្វែងរក និងបណ្តុះបណ្តាល<br>- ប្រសិទ្ធភាពនៃកិច្ចសហការជាមួយរដ្ឋាភិបាល | ស្តីពីចិត្តសាស្ត្រសង្គម ឧទេសដោយអ្នកឯកទេសគ្រប់គ្រងករណី ដោយមានការគាំទ្រពីហ្វ្រេនឡអិនធើណាសិនណល។<br>- បន្តការគាំទ្រដល់ប្រធានក្រុមគ្រប់តំបន់ និងអ្នកគ្រប់គ្រងករណីក្នុងការអនុវត្តប្រព័ន្ធនៃការគ្រប់គ្រងករណី។<br>- បុគ្គលិក ៥0 នាក់ កំពុងធ្វើការជាអ្នកគ្រប់គ្រងករណីប្រកបដោយគុណភាព។<br>- បានចូលរួមប្រជុំការគ្រប់គ្រងករណីចំនួន ៦0 ដង ជាមួយប្រធានក្រុមតំបន់ទាំង អស់នៃក្រុមតាមថ្នល់ និងប្រធានមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ។<br>**ឧបករណ៍**<br>- សៀវភៅណែនាំស្តីពីការគ្រប់គ្រងករណី ដែលមានស្រាប់កំពុងប្រើប្រាស់ក្នុងត្រីមាសនេះ។<br>**ដៃគូ**<br>- បានទស្សនកិច្ចទៅអង្គការបាការ និងអង្គការទស្សនៈពិភពលោក ដើម្បីដាក់បញ្ចូលនៅទៅក្នុងបញ្ជីសេវាកម្ម ដោយមានកិច្ចសហការពីអង្គការហ្វ្រេនឡអ៊ិនធើណាសិនណល។<br>- បានចូលរួមប្រជុំជាមួយអង្គការក្រុមប្រឹក្សាសកម្មភាពជនពិការ ដើម្បីធ្វើកំណែទម្រង់គម្រោង នាថ្ងៃទី៣0 ខែមីនា ឆ្នាំ២០១២។<br>- បានចូលរួមប្រជុំជាមួយអង្គការជួយជនរងគ្រោះដោយសារអាស៊ីត ដើម្បីចែករំលែកព័ត៌មាន ស្តីពីសេវាកម្មរបស់អង្គការមិត្តសំឡាញ់សម្រាប់ជនរងគ្រោះដោយ សារទឹកអាស៊ីត នាថ្ងៃទី១៦ ខែមករា ឆ្នាំ២០១២។ |

| | | |
|---|---|---|
| **៥.៥ ក្រុមជំនាញផ្នែកគ្រឿងញៀន** | **លទ្ធផលរំពឹងទុក:**<br>- ម្ជុល/ស៊ីរ៉ាំងចំនួន ២០០,០០០ នឹងចែកចាយដល់យុវវ័យ<br>- សេវាលើការកាត់បន្ថយភាពមានគ្រោះថ្នាក់ដោយគ្រឿងញៀនចំនួន ៧០,០០០ សេវា នឹងផ្តល់ជូនយុវវ័យ<br>- កុមារ/យុវវ័យចំនួន ២០០នាក់ នឹងទទួលបានសេវាបន្សាបគ្រឿងញៀន និងស្តារនីតិសម្បទា (យកទិន្នន័យ ពីក្រុមតាមថ្នល់)<br>**ការតាមដាន វាយតម្លៃ និងស្រាវជ្រាវ**<br>- ប្រព័ន្ធនៃការត្រួតពិនិត្យនិងប្រមូលទិន្នន័យ គឺជាសូចនាករជាលក្ខណៈស្តង់ដា នៃកម្មវិធីប្រេន្ទ្យអ៊ិនធើណាសិនណលសម្រាប់សកម្មភាពគ្រឿងញៀន<br>- ការវាយតម្លៃលើសកម្មភាពដែលទាក់ទងជាមួយគ្រឿងញៀន (បំណិនជីវិត ការកាត់បន្ថយគ្រោះថ្នាក់នៃថ្នាំញៀនការបន្សាបគ្រឿងញៀន)<br>- ចងក្រងរបាយការណ៍សំរាប់មិត្តសំឡាញ់ ម្ចាស់ជំនួយ និងរដ្ឋាភិបាល<br>- រៀបចំការស្រាវជ្រាវមួយលើការស្ទង់មតិគ្រឿងញៀនប្រចាំឆ្នាំ<br>**ការគាំទ្របច្ចេកទេស**<br>- បុគ្គលិក១០០% នឹងទទួលបានការបណ្តុះបណ្តាលលើចំណេះដឹងគ្រឿងញៀនជាមូលដ្ឋាន<br>- នឹងផ្តល់ការគាំទ្របច្ចេកទេសជារៀងរាល់សប្តាហ៍ តាមរយៈការងារនៅតាមមូលដ្ឋានជាមួយក្រុមទាំងអស់<br>**ឧបករណ៍**<br>- សម្ភារៈអប់រំទៅលើគ្រឿងញៀននឹងត្រួតពិនិត្យនិងធ្វើបច្ចុប្បន្នភាពជាប្រចាំ | **លទ្ធផលសំរេចបាន:**<br>- ម្ជុល/ស៊ីរ៉ាំងចំនួន ៣៦,៥៩៨ បានចែកចាយដល់យុវវ័យ<br>- សេវាលើការកាត់បន្ថយភាពមានគ្រោះថ្នាក់ដោយគ្រឿងញៀនចំនួន ១៦,៦៩៤ សេវាបានផ្តល់ជូនយុវវ័យ<br>- កុមារ/យុវវ័យចំនួន ៨៦ នាក់បានទទួលសេវាបន្សាបគ្រឿងញៀន និងស្តារនីតិសម្បទា នាត្រីមាសនេះ<br>**ការតាមដាន វាយតម្លៃ និងស្រាវជ្រាវ**<br>- អង្គការមិត្តសំឡាញ់ បានទទួលអាជ្ញាប័ណ្ណកម្មវិធីម្ជុល/ស៊ីរ៉ាំងសម្រាប់ឆ្នាំ២០១២ ពីអាជ្ញាធរជាតិ ប្រយុទ្ធប្រឆាំងគ្រឿងញៀន ដើម្បីបន្តដំណើរការអនុវត្តកម្មវិធីម្ជុល/ស៊ីរ៉ាំង។<br>- ការអង្កេតគ្រឿងញៀនប្រចាំឆ្នាំ ២០១១ បានបញ្ចប់ និងផ្ញើរជូនជំនួយការបច្ចេកទេសនៃអង្គការប្រេន្ទ្យអ៊ិនធើណាសិនណល ដើម្បីបូកសុបលទ្ធផលសម្រាប់រយៈពេល៥ឆ្នាំ ចាប់ពីឆ្នាំ២០០៧ ដល់ឆ្នាំ២០១១។<br>- បានចងក្រងរបាយការណ៍ប្រចាំខែ/ត្រីមាសជូនមិត្តសំឡាញ់ អង្គការប្រេន្ទ្យអ៊ិនធើណាសិនណលនិងអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។<br>- បានធ្វើការប៉ាន់ប្រមាណប្រចាំខែលើកម្មវិធីម្ជុល/ស៊ីរ៉ាំងជាមួយអ្នកចាក់គ្រឿងញៀននៅគ្រប់តំបន់ទាំងអស់នៃក្រុមតាមថ្នល់ ដោយមានកិច្ចសហការពីអង្គការប្រេន្ទ្យអ៊ិនធើណាសិនណល។<br>**ការគាំទ្របច្ចេកទេស**<br>- បុគ្គលិកចំនួន ២៥នាក់ បានទទួលការបណ្តុះបណ្តាលលើចំណេះដឹងគ្រឿងញៀនជា |

| | | |
|---|---|---|
| | - សៀវភៅណែនាំនឹងរៀបចំអនុវត្ត និងធ្វើបច្ចុប្បន្នភាពជាទៀងទាត់<br><br>**ដៃគូ**<br>- បង្កើត ប្រើប្រាស់ និងធ្វើបច្ចុប្បន្នភាពបញ្ជីសេវាកម្មជារៀងរាល់ឆ្នាំ និងចែករំលែកជាមួយក្រុមទាំងអស់<br>- បុគ្គលិកអង្គការដៃគូ ៣០ នាក់នឹងត្រូវបានស្វែងរក និងបណ្តុះបណ្តាល<br>- ប្រសិទ្ធិភាពនៃកិច្ចសហការជាមួយរដ្ឋាភិបាល | មូលដ្ឋាននៅតាមថ្នល់ មជ្ឈមណ្ឌលបន្សាប និងស្ថានីពិសម្បទា ក្នុងត្រីមាសនេះ។<br>- បានចុះមូលដ្ឋានចំនួន ៤២ដង ក្នុង ៥តំបន់មណ្ឌលសំចតចល័ត មណ្ឌលស្នាក់នៅបណ្តោះអាសន្ន មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ និងមជ្ឈមណ្ឌលអប់រំ ដើម្បីផ្តល់ការគាំទ្រផ្នែកបច្ចេកទេស។<br>- ផ្ទៀងផ្ទាត់ទិន្និន័យនៃអ្នកប្រើប្រាស់គ្រឿងញៀន និងអ្នកចាក់គ្រឿងញៀន ជាមួយក្រុមតាមថ្នល់សម្រាប់ធ្វើរបាយការណ៍ជូន ម្ចាស់មូលនិធិរួមមាន: Global Fund និងAusAID/HAARP ។<br>**ឧបករណ៍**<br>- ធ្វើការតាមដានលើការអនុវត្តនៃសម្ភារៈអប់រំលើការកាត់បន្ថយភាពមានគ្រោះថ្នាក់ដោយគ្រឿងញៀន និងសម្ភារៈ អប់រំលើការបង្កាទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀនជាមួយក្រុមតាមថ្នល់ក្នុងគោលបំណងដើម្បីធ្វើការកែលំអរប្រសិនបើចាំបាច់។<br>- បន្តដំណើការក្រុមណាកូទិចអាណាមិក Narcotic Anonymous ដើម្បីជួយអតីតអ្នកប្រើប្រាស់គ្រឿងញៀន អោយបន្តចាកផុតពីការត្រឡប់ទៅប្រើប្រាស់គ្រឿងញៀនវិញ ដែលពួកគេកំពុងសិក្សានៅមជ្ឈមណ្ឌលអង្គការមិត្តសំឡាញ់ដោយកិច្ចសហការជាមួយប្រេនឡអ៊ិនធើណាសិនណល។<br>- សៀវភៅណែនាំសម្រាប់ផ្ទះបៃតងកំពុងព្រាងនៅឡើយជាមួយជំនួយការបច្ចេកទេសនៃអង្គការប្រេនឡអ៊ិនធើណាសិនណល។<br>**ដៃគូ**<br><u>ការប្រជុំនិងកិច្ចសហការជាមួយរដ្ឋាភិបាល/អង្គការដៃគូ:</u><br>- បុគ្គលិក១៨នាក់ មកពីស្មុខភាពគ្រួសារអន្តរជាតិ អង្គការកសាង មជ្ឈមណ្ឌល |

| | | |
|---|---|---|
| | | សុខភាពបុរស និងសមាគមន៍ស្ត្រីកម្ពុជា បានទទួលការថែកាំរំលែកបទពិសោធន៍ស្តីពីការដំណើរការនៃការអនុវត្តកម្មវិធីម្ជុល/ស៊ីរ៉ាំង និងបានចុះតាមដានផ្ទាល់ ជាមួយក្រុមការងារ នៅថ្ងៃទី២០-២១ ខែមីនា ឆ្នាំ២០១២។<br>- បានចុះទស្សនកិច្ចសិក្សាលើគម្រោងទាំងអស់នៃអង្គការកល្យាណមិត្ត នៅថ្ងៃទី ៣០ ខែមករា និងថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០១២។<br>- បានចូលរួមប្រជុំយ៉ាងទៀតទាត់ជាមួយក្រុមចំបង សម្របសម្រួលដោយអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ ដើម្បីបង្កើតផែនការថ្នាក់ជាតិពាក់ព័ន្ធទៅនឹងការបន្តការបង្ការ ការថែរក្សា ការព្យាបាល និងស្តង់ដានីតិសម្បទាសម្រាប់អ្នកប្រើប្រាស់គ្រឿងញៀន និងអ្នកចាក់គ្រឿងញៀន ជាលទ្ធផលផែនការយុទ្ធសាស្ត្របានដាក់ជូនរដ្ឋមន្ត្រីក្រសួងសុខាភិបាល និងប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនដើម្បីធ្វើការសំរេច។<br>- បានចូលរួមកិច្ចប្រជុំយ៉ាងទៀតទាត់ជាមួយក្រុមចំបង ដែលសម្របសម្រួលដោយមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ និងអង្គការសហប្រជាជាតិ ដើម្បីពិនិត្យឡើងវិញលើការអនុវត្តការផ្តល់សេវាកម្មសម្រាប់ប្រជាជនដែល ប្រឈមមុខខ្ពស់ និងបង្កើតបទដ្ឋាននៃនីតិវិធីពាក់ព័ន្ធទៅនឹងស្ត្រីបំរើសេវាកម្សាន្ត បុរស ស្រឡាញ់បុរស អ្នកប្រើប្រាស់គ្រឿងញៀន/អ្នកចាក់គ្រឿងញៀន និងក្រុមប្រឈមមុខថ្មី ដើម្បីសម្រេចផែនការយុទ្ធសាស្ត្រជាតិ សូន្យបី ២០១១ – ២០២០។<br>- បានចូលរួមប្រជុំនៅក្នុងគណៈកម្មាធិការដឹកនាំ ស្តីពីការប៉ាន់ប្រមាណថ្នាក់ជាតិ |

| | | |
|---|---|---|
| | | សម្រាប់អ្នកប្រើប្រាស់គ្រឿងញៀន/អ្នកចាក់គ្រឿងញៀន ដែលសម្របសម្រួលដោយអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន នាថ្ងៃទី ១៤ ខែកុម្ភៈ ឆ្នាំ ២០១២។<br>- មន្ត្រីម្នាក់មកពីការិយាល័យអង្គការសហប្រជាជាតិប្រឆាំងគ្រឿងញៀន និងឧក្រិដ្ឋកម្ម បានមកទស្សនកិច្ចសិក្សាលើកម្មវិធីទាំងអស់របស់អង្គការមិត្តសំឡាញ់ នាថ្ងៃទី ០៩ ខែមីនា ឆ្នាំ២០១២។<br>**ព្រឹត្តិការណ៍និងករណីសម្គាល់ពិសេស**<br>- ប៉ូលីស និងអាជ្ញាធរមូលដ្ឋានបានចាប់កុមារ/យុវវ័យនៅតាមផ្លូវក្នុងរាជធានីភ្នំពេញកំឡុងពេលកិច្ចប្រជុំអាស៊ាន ហើយបានបញ្ជូនទៅមន្ទីរសង្គមកិច្ចរាជធានីភ្នំពេញ ដើម្បីឆ្លើយតបទៅនឹងបញ្ហានេះ ក្រុមតាមផ្លូវបានរៀបចំកុមារ/យុវវ័យឱ្យទៅលេងនៅជុំរុំសប្បាយសប្បាយនៃអង្គការមិត្តសំឡាញ់នៅខេត្តកំពង់ស្ពឺ។<br>- មន្ត្រីប៉ូលីសចំនួន ០១ នាក់ បានបន្តស្ម័គ្រចិត្តប្រមូលម្ជុល/សឺរាំងនៅតំបន់តាន់ប៉ាសង្កាត់ ផ្សារថ្មី២ ។ |
| **៥.៦ ក្រុមឯកទេស ផ្នែកអប់រំក្រៅប្រព័ន្ធ** | **លទ្ធផលរំពឹងទុកៈ**<br>- សេវានៃការអប់រំក្រៅប្រព័ន្ធចំនួន ១២២,០០០ នឹងផ្ដល់ដល់កុមារ/យុវវ័យនៅតាមផ្លូវ មជ្ឈមណ្ឌលអប់រំ និងមជ្ឈមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈ<br><br>**ការតាមដាន វាយតម្លៃ និងស្រាវជ្រាវ**<br>- ប្រព័ន្ធនៃការត្រួតពិនិត្យនិងប្រមូលទិន្នន័យ គឺជាសូចនាករលក្ខណៈស្តង់ដានៃកម្មវិធីប្រេឡូអ៊ិនធើណាសិនណលសម្រាប់សកម្មភាព អប់រំក្រៅប្រព័ន្ធជាមួយក្រុមអប់រំតាមផ្លូវ<br>- ចងក្រងរបាយការណ៍សំរាប់មិត្តសំឡាញ់ ម្ចាស់ជំនួយ និងរដ្ឋាភិបាល | **លទ្ធផលសំរេចបានៈ**<br>- សេវានៃការអប់រំក្រៅប្រព័ន្ធចំនួន ៤២,៨៦៦ (ស្រី ១៦,១៧៩ ដង) បានផ្ដល់ដល់កុមារ/យុវវ័យ នៅតាមផ្លូវ មជ្ឈមណ្ឌលអប់រំ និងមជ្ឈមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈ ។<br><br>**ការតាមដាន វាយតម្លៃ និងស្រាវជ្រាវ**<br>- បានចុះមូលដ្ឋានចំនួន ១៥ដង នៅ ៥តំបន់ ដើម្បីតាមដានថាឧបករណ៍សិក្សាបានប្រើប្រាស់ ព្រមទាំងគាំទ្រអ្នកអប់រំលើវិធីសាស្ត្រក្នុងការដំណើរការឧបករណ៍សិក្សា។<br>- បានចងក្រងរបាយការណ៍ប្រចាំត្រីមាសជូនមិត្តសំឡាញ់ ។ |

| | | |
|---|---|---|
| | - ការវាយតម្លៃលើសកម្មភាពអប់រំក្រៅប្រព័ន្ធ<br>- រៀបចំការស្រាវជ្រាវមួយ<br>**ការគាំទ្របច្ចេកទេស**<br>- បុគ្គលិក៦០នាក់នឹងទទួលបានការបណ្តុះបណ្តាលស្តីពីសកម្មភាពអប់រំក្រៅប្រព័ន្ធ<br>- ជំនួយការបច្ចេកទេស នឹងផ្តល់ការគាំទ្របច្ចេកទេសជារៀងរាល់សប្តាហ៍តាមរយៈការចុះនៅតាមមូលដ្ឋាន ជាមួយមជ្ឈមណ្ឌលអប់រំ និងក្រុមការងារតាមថ្នល់<br>**ឧបករណ៍**<br>- សម្ភារៈអប់រំក្រៅប្រព័ន្ធថ្មី នឹងត្រូវបង្កើតនិងធ្វើបច្ចុប្បន្នភាព<br>- សៀវភៅណែនាំ ស្តីពីការអប់រំក្រៅប្រព័ន្ធ នៅតាមថ្នល់ ក្នុងមណ្ឌល និងសមាហរណកម្មទៅសាលារដ្ឋ នឹងបង្កើត អនុវត្ត និងធ្វើបច្ចុប្បន្នភាពជាទៀងទាត់<br>**ដៃគូ**<br>- នឹងបង្កើត ប្រើប្រាស់ និងធ្វើបច្ចុប្បន្នភាពបញ្ជីសេវាកម្មជារៀងរាល់ឆ្នាំ និងចែករំលែកជាមួយក្រុមការងារទាំងអស់<br>- បុគ្គលិកអង្គការដៃគូ ៣០នាក់នឹងត្រូវបានស្វែងរក និងបណ្តុះបណ្តាល<br>- ប្រសិទ្ធិភាពនៃកិច្ចសហការជាមួយរដ្ឋាភិបាល | **ការគាំទ្របច្ចេកទេស**<br>- បុគ្គលិកមិត្តសំឡាញ់ចំនួន ១៣នាក់ (ស្រី០៧នាក់) បានទទួលវគ្គរំលឹកឡើងវិញស្តីពីរបៀបប្រើប្រាស់ឧបករណ៍សិក្សា ឧទ្ទេសដោយអ្នកឯកទេសអប់រំក្រៅប្រព័ន្ធ។<br>- បុគ្គលិកមិត្តសំឡាញ់ចំនួន ០៥នាក់ (ស្រី ០៣នាក់) បានទទួលការបណ្តុះបណ្តាលផ្នែកកុមារតូច ឧទ្ទេសដោយជំនួយការបច្ចេកទេសនៃអង្គការកល្យាណមិត្ត សហការជាមួយអ្នកឯកទេសអប់រំក្រៅប្រព័ន្ធ។<br>**ឧបករណ៍**<br>- សៀវភៅណែនាំ ស្តីពីការអប់រំក្រៅប្រព័ន្ធក្នុងមណ្ឌល កំពុងកែសម្រួលបន្ទាប់ពីអ្នកសម្របសម្រួលកម្មវិធី បានត្រួតពិនិត្យ ហើយនឹងបញ្ចប់នៅក្នុងត្រីមាសទី២។<br>- សៀវភៅណែនាំចំនួន២ ស្តីពីអប់រំក្រៅប្រព័ន្ធនៅតាមថ្នល់ និងនៅសាលារដ្ឋបានត្រួតពិនិត្យ ដោយអ្នកសម្របសម្រួលកម្មវិធី។<br>**ដៃគូ**<br>- បុគ្គលិកអង្គការកុមាររីករាយ អង្គការហ្វាព្រៃសិល្បៈ អង្គការដំណក់ទឹកប៉ោយប៉ែត បានទទួលការបណ្តុះបណ្តាលស្តីពីរបៀបប្រើប្រាស់ឧបករណ៍សិក្សា។<br>- បុគ្គលិករដ្ឋាភិបាលចំនួន ៣៨នាក់ (ស្រី ២២នាក់) បានទទួលការបណ្តុះបណ្តាលស្តីពីរបៀបប្រើប្រាស់ឧបករណ៍សិក្សាដោយមានកិច្ចសហការពីមន្ទីរអប់រំយុវជន និងកីឡារាជធានីភ្នំពេញ។<br>- បុគ្គលិកអង្គការប្រេនឡអ៊ិនធើណាសិនណាលចំនួន ១ បានទទួលការពណ្តុះបណ្តាលស្តីពីរបៀបប្រើប្រាស់ឧបករណ៍សិក្សា។ |

| | | |
|---|---|---|
| | | **ព្រឹត្តិការណ៍និងសកម្មភាពសំខាន់ពិសេស**<br>- បានចូលរួមប្រជុំពិគ្រោះយោបល់ដើម្បីបង្កើតអនុប្រធានបណ្ណាញថ្នាក់ជាតិលើផ្នែកអប់រំ សម្របសម្រួលដោយ អង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល (NEP) នាថ្ងៃទី ០២ ខែកុម្ភៈ ឆ្នាំ២០១២។<br>- បានធ្វើបទបង្ហាញស្តីពីរបៀបប្រើប្រាស់ឧបករណ៍សិក្សាទៅដល់អង្គការផ្សេងៗនៅក្រុមការងារផ្នែកអប់រំក្រៅប្រព័ន្ធ រៀបចំដោយអង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល(NEP) នាថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១២។ |
| **៥.៧ ក្រុមឯកទេសផ្នែកបំណិនជីវិត** | **លទ្ធផលរំពឹងទុក:**<br>- សេវាអប់រំបំណិនជីវិតចំនួន ២៨០,០០០ នឹងផ្តល់ដល់កុមារ/យុវវ័យ<br>- សេវាអប់រំបំណិនជីវិតចំនួន ៩០,០០០ នឹងផ្តល់ដល់អាណាព្យាបាល<br>- ស្រោមអនាម័យចំនួន ២៥០,០០០ នឹងចែកជូនយុវវ័យ<br>- មិត្តអប់រំមិត្តចំនួន ២៧០នាក់ (ភ្នាក់ងារសុវត្ថិភាពចំនួន ១៥០នាក់)<br>- សេវាអប់រំមេរោគអេដស៍/ជម្ងឺអេដស៍ចំនួន ៥២,០០០<br>- សេវាអប់រំសុខភាពបន្តពូជចំនួន ៥៥,០០០<br>- សេវាអប់រំគ្រឿងញៀនចំនួន ៥០,០០០<br>- សេវាអប់រំសិទ្ធិកុមារចំនួន ២៥,០០០<br><br>**ការតាមដាន វាយតម្លៃ និងស្រាវជ្រាវ**<br>- ប្រព័ន្ធនៃការត្រួតពិនិត្យនិងប្រមូលទិន្នន័យ គឺជាសូចនាករលក្ខណៈស្តង់ដានៃកម្មវិធីប្រឡូអ៊ិនធើណាសិនណាលសម្រាប់បំណិនជីវិត ជាមួយការអប់រំក្រុមការងារតាម | **លទ្ធផលសំរេចបាន:**<br>- សេវាអប់រំបំណិនជីវិតចំនួន ៨១,៣៦២ បានផ្តល់ដល់កុមារ/យុវវ័យ<br>- សេវាអប់រំបំណិនជីវិតចំនួន ២៩,៥០៩ បានផ្តល់ដល់អាណាព្យាបាល<br>- ស្រោមអនាម័យចំនួន ៥៩,៥០៨ បានចែកជូនយុវវ័យ<br>- មិត្តអប់រំមិត្តចំនួន ២៣២នាក់ (ស្រី ៧៤នាក់ ) ក្នុងនោះមានភ្នាក់ងារសុវត្ថិភាពចំនួន ១៧២នាក់ (ស្រី៥២នាក់)<br>- សេវាអប់រំមេរោគអេដស៍/ជម្ងឺអេដស៍ចំនួន ១៤,៨៣៥<br>- សេវាអប់រំសុខភាពបន្តពូជចំនួន ១៦,៣៦២<br>- សេវាអប់រំគ្រឿងញៀនចំនួន ១៣,៣៨៨<br>- សេវាអប់រំសិទ្ធិកុមារចំនួន ៩,៥៧៣<br>**ការតាមដាន វាយតម្លៃ និងស្រាវជ្រាវ**<br>- ការអង្កេតស្ទាបស្ទង់លើការយល់ដឹងពីមេរោគអេដស៍/ជំងឺអេដស៍ បានបញ្ចប់ និងធ្វើបទបង្ហាញដល់ក្រុមតាមថ្នាក់និងគណៈគ្រប់គ្រង។ |

| | | |
|---|---|---|
| | ថ្នល់<br>- ផងក្រងរបាយការណ៍សំរាប់មិត្តសំឡាញ់ ម្ចាស់ជំនួយ និង រដ្ឋាភិបាល<br>- ការវាយតម្លៃលើសកម្មភាពបំណិនជីវិត<br>- រៀបចំការស្រាវជ្រាវមលើបំណិនជីវិតប្រចាំឆ្នាំ<br>**ការគាំទ្របច្ចេកទេស**<br>- បុគ្គលិកចំនួន ៥0នាក់ នឹងទទួលបានបណ្តុះបណ្តាលស្តីពីសកម្មភាពបំណិនជីវិត<br>- នឹងផ្តល់គាំទ្របច្ចេកទេសជារៀងរាល់សប្តាហ៍តាមរយៈការធ្វើការនៅតាមមូលដ្ឋាន ជាមួយការអប់រំក្រុមតាមថ្នល់<br>**ឧបករណ៍**<br>- សម្ភារៈអប់រំថ្មី នឹងបង្កើត និងធ្វើបច្ចុប្បន្នភាព<br>- សៀវភៅណែនាំស្តីពីបំនិនជីវិត នឹងបង្កើត អនុវត្ត និងធ្វើបច្ចុប្បន្នភាពជាទៀងទាត់<br>**ដៃគូ**<br>- បុគ្គលិកអង្គការដៃគូចំនួន ៣0នាក់ នឹងត្រូវបានស្វែងរក និងបណ្តុះបណ្តាល<br>- ប្រសិទ្ធិភាពនៃកិច្ចសហការជាមួយរដ្ឋាភិបាល | - បានផងក្រងរបាយណ៍ប្រចាំខែ និងត្រីមាសជូនមិត្តសំឡាញ់ ។<br>**ការគាំទ្របច្ចេកទេស**<br>- បានចុះមូលដ្ឋានចំនួន ៦0ដង នៅតំបន់ទាំង ៥ នៃក្រុមតាមថ្នល់ មណ្ឌលសំចត មជ្ឈមណ្ឌលអប់រំ និងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ។<br>- បុគ្គលិកមិត្តសំឡាញ់ចំនួន 0៦នាក់ (ស្រី0៣នាក់) បានទទួលវគ្គរំលឹកឡើងវិញស្តីពីរបៀបប្រើប្រាស់សម្ភារៈអប់រំ និងល្បែងបំណិនជីវិត។<br>- បានចូលរួមជួយសម្របសម្រួលនៅក្នុងក្រុមគាំទ្រផ្លូវចិត្តជាមួយអាណាព្យាបាលនៅតំបន់អូឡាំពិករៀងរាល់២សប្តាហ៍ ។<br>**ឧបករណ៍**<br>- សម្ភារៈអប់រំសុវត្ថិភាព និងអនាម័យសម្រាប់មជ្ឈមណ្ឌលបណ្តុះបណ្តាល វិជ្ជាជីវៈ បានកែសម្រួលបន្ទាប់ពីបានត្រួតពិនិត្យ ដោយអ្នកសម្របសម្រួលកម្មវិធី។<br>**ដៃគូ**<br>- បានទស្សនកិច្ចនៅអង្គការ Jesuit Service Cambodia (JSC) កម្ពុជា ដើម្បីដាក់បញ្ចូលនៅទៅក្នុងបញ្ជីសេវាកម្ម ដោយមានកិច្ចសហការពីអង្គការប្រេន្ទអ៊ិនធើណាសិនណល។ |
| **៥.៨ ក្រុមឯកទេសបណ្តាញសុវត្ថិភាពកុមារ** | **លទ្ធផលរំពឹងទុក:**<br>- នឹងមានសមាជិកបណ្តាញសុវត្ថិភាពកុមារនាពេលបច្ចុប្បន្នចំនួន ១,000នាក់ រួមបញ្ចូលបណ្តាញសុវត្ថិភាពកុមារនៅសហគមន៍ នៅរាជធានីភ្នំពេញនិងកំពង់ចាម<br>- កុមារចំនួន ១,១00នាក់ នឹងទទួលបានការការពារនិងបញ្ជូនដោយសមាជិកបណ្តាញ | **លទ្ធផលសំរេចបាន:**<br>- សមាជិកបណ្តាញសុវត្ថិភាពកុមារនាពេលបច្ចុប្បន្នមានចំនួន ៦៨៦ នាក់ (ស្រី៩៥ នាក់) ក្នុងនោះមានថ្មី២៧នាក់ (ម៉ូតូឌុប ៣0១នាក់, ម៉ូតូរម៉ក ២៣៧នាក់, តាក់ស៊ី ៦នាក់) រួមបញ្ចូលបណ្តាញសុវត្ថិភាពកុមារនៅសហគមន៍ ចំនួន១៤២នាក់ (ស្រី ៩៥នាក់) នៅរាជធានីភ្នំពេញនិងកំពង់ចាម។ |

| | | |
|---|---|---|
| | សុវត្ថិភាពកុមារ<br><br>**ការតាមដាន វាយតម្លៃ និងស្រាវជ្រាវ**<br>- ប្រព័ន្ធនៃការត្រួតពិនិត្យនិងប្រមូលទិន្នន័យ គឺជាសូចនាករលក្ខណៈស្តង់ដានៃកម្មវិធីប្រហ្វេនអ៊ិនធើណាស៊ិនណលសំរាប់បណ្តាញសុវត្ថិភាពកុមារ<br>- ការវាយតម្លៃលើបណ្តាញសុវត្ថិភាពកុមារក្នុងរាជធានីភ្នំពេញនិងខេត្តកំពង់ចាម<br>- ចងក្រងរបាយការណ៍សំរាប់មិត្តសំឡាញ់ ម្ចាស់ជំនួយ និងរដ្ឋាភិបាល<br>- រៀបចំការស្រាវជ្រាវមួយ<br><br>**ការគាំទ្របច្ចេកទេស**<br>- បុគ្គលិក១00% នឹងទទួលបានបណ្តុះបណ្តាលស្តីពីសកម្មភាពបណ្តាញសុវត្ថិភាពកុមារ<br>- នឹងផ្តល់ការគាំទ្របច្ចេកទេសជារៀងរាល់សប្តាហ៍តាមរយៈការចុះមូលដ្ឋានជាមួយក្រុមការងារទាំងអស់<br>- ពិនិត្យមើលសំភារៈនៅក្នុងឃ្លាំង និងបញ្ជាទិញសំភារៈថ្មីៗសម្រាប់សមាជិកបណ្តាញសុវត្ថិភាពកុមារ<br>**ឧបករណ៍**<br>- សម្ភារៈអប់រំបណ្តាញសុវត្ថិភាពកុមារនឹងត្រួតពិនិត្យនិងធ្វើបច្ចុប្បន្នភាពជាប្រចាំ<br>- សៀវភៅណែនាំស្តីពីបណ្តាញសុវត្ថិភាពកុមារ នឹងបង្កើត អនុវត្ត និងធ្វើបច្ចុប្បន្នភាពជាទៀងទាត់ | - សេវាចំនួន ២៤៥ នាក់ នៃការកុមារ/យុវវ័យបានទទួលការការពារ និងបញ្ជូនមកអង្គការមិត្តសំឡាញ់ មន្ទីរពេទ្យ និងហៅទូរស័ព្ទទៅទូរស័ព្ទបន្ទាន់និងប៉ូលីស ដោយសមាជិកបណ្តាញសុវត្ថិភាពកុមារ។<br>**ការតាមដាន វាយតម្លៃ និងស្រាវជ្រាវ**<br>- សមាជិកសុវត្ថិភាពកុមារបានតាមដាន និងរំលឹកឡើងវិញចំនួន ១៣៩៥ ដង ក្នុងត្រីមាសនេះ។<br>- សមាជិកសុវត្ថិភាពចំនួន ២២៣ នាក់ បានតាមដាន ដោយការប្រើប្រាស់ទម្រង់នៃការតាមដាន ធ្វើឡើងដោយបុគ្គលតាមផ្ទះល់ នៅភ្នំពេញនិងកំពង់ចាម។<br>- បានចងក្រងរបាយការណ៍ប្រចាំត្រីមាស ជូនមិត្តសំឡាញ់ និងអង្គការប្រហ្វេនអ៊ិនធើណាស៊ិនណាល។<br>**ការគាំទ្របច្ចេកទេស**<br>- បានចុះមូលដ្ឋានចំនួន ៥៥ដង ដើម្បីជួបប្រជុំជាមួយសមាជិកសុវត្ថិភាពកុមារ និងគាំទ្រ ដល់បុគ្គលិកនៅតំបន់ទាំង ៥នៃក្រុមតាមផ្ទះល់។<br>**ឧបករណ៍**<br>- ទម្រង់នៃការតាមដានសមាជិកសុវត្ថិភាពកុមារបានកែសម្រួលដោយអ្នកឯកទេសសុវត្ថិភាពកុមារ សហការជាមួយអង្គការប្រហ្វេនអ៊ិនធើណាស៊ិនណល។<br>- សៀវភៅណែនាំស្តីពីបណ្តាញសុវត្ថិភាពកុមារបានបញ្ចប់ ហើយត្រៀមបណ្តុះបណ្តាលដល់បុគ្គលិកតាមផ្ទះល់នាត្រីមាសក្រោយ។ |

| | | |
|---|---|---|
| | **ដៃគូ**<br>- បង្កើត ប្រើប្រាស់ និងធ្វើបច្ចុប្បន្នភាពបញ្ជីសេវាកម្មជារៀងរាល់ឆ្នាំ និងចែករំលែកជាមួយក្រុមទាំងអស់<br>- បុគ្គលិកអង្គការដៃគូចំនួន ៤០នាក់ នឹងត្រូវបានស្វែងរក និងបណ្តុះបណ្តាលតាមរយៈប្រព័ន្ធអ៊ិនធើណាសិនណល<br>- ប្រសិទ្ធិភាពនៃកិច្ចសហការជាមួយរដ្ឋាភិបាល | **ដៃគូ**<br>ការប្រជុំនិងកិច្ចសហការជាមួយរដ្ឋាភិបាល/អង្គការដៃគូ:<br>- បានចូលរួមវគ្គបណ្តុះបណ្តាលរំលឹកឡើងវិញស្តីពីក្មេងប្រុសជាចំបង នៅអង្គការដំហានដំបូង នាថ្ងៃទី១-៣ ខែកុម្ភៈ ឆ្នាំ២០១២។<br>- បានចូលរួមសិក្ខាសាលស្តីពី សិទ្ធិជួយកុមាររងគ្រោះដោយការជួញដូរ រៀបចំដោយគណៈកម្មាធិការបំបាត់ វេស្យាចារ ការរំលោភ និងជួញដូរកុមារនៅកម្ពុជា (ECPAT) នាថ្ងៃទី២៦-២៧ ខែមីនា ឆ្នាំ២០១២។<br>**ព្រឹត្តិការណ៍និងករណីសម្គាល់ពិសេស**<br>- សមាជិកបណ្តាញសុវត្ថិភាពចំនួន ៥២នាក់ បានលប់ឈ្មោះចេញពីបញ្ជីឈ្មោះសមាជិកសុវត្ថិភាពកុមារ ក្នុងត្រីមាសនេះដោយសារ ពួកគាត់មិនបានគោរពគោលការណ៍ការពារកុមារ ផ្លាស់ប្តូរមុខរបរនិងខ្លះទៀតប្រឡប់ទៅស្រុកកំណើតវិញ។ |